## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
លេខ: ២២៦/១៤ ក.អ.ជ.ប្រក

ថ្ងៃអង្គារ ៨ រោច ខែភទ្របទ ឆ្នាំមមី ព.ស.២៥៥៨
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា គ.ស. ២០១៤

**សេចក្តីសម្រេច**
**ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការកណ្តាល**
**និងអនុគណៈកម្មការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងអភិវឌ្ឍន៍ជនបទ**

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩១៣/៩០៣ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញបទបញ្ជា លេខ ៣០ បប ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- យោងសារាចរណែនាំលេខ ០០១ សហវ.ទរ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

– យោងលិខិតលេខ ៦០៧ សហវ.ទរ ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីសំណើរៀបចំធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមគំរូថ្មី

**<u>សម្រេច</u>**

**ប្រការ ១** .– បង្កើតគណៈកម្មការកណ្តាលធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ឲ្យទទួលបន្ទុកណែនាំ និងអនុវត្តការងារធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម **ស្នួស គង់** | រដ្ឋលេខាធិការ | អនុប្រធានទី ១ |
| ៣- | ឯកឧត្តម **ហ្មួត សារឹម** | អនុរដ្ឋលេខាធិការ | អនុប្រធានទី ២ |
| ៤- | ឯកឧត្តម **ជួប សំអាត** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៥- | ឯកឧត្តម **ចាន់ ដារ៉ុង** | អគ្គនាយកបច្ចេកទេស | សមាជិក |
| ៦- | ឯកឧត្តម **ម៉ិន ច័ន្ទវណ្ណៈ** | អគ្គាអធិការ | សមាជិក |
| ៧- | លោកបណ្ឌិត **យ៉ាន់ វ៉ាន់ដីលុច** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៨- | លោក **ឃាន សុម៉ារ៉ា** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ | សមាជិក |
| ៩- | លោក **ធួន តិរម្យ** | ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ១០- | លោក **យ៉ីន សុផល** | ប្រធាននាយកដ្ឋានផ្លូវលំជនបទ | សមាជិក |
| ១១- | លោក **ម៉ា សុវណ្ណា** | ប្រធាននា.ផែនការ និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ១២- | លោកវេជ្ជ.**ហ្វូ កុលច័ន្ទ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ១៣- | លោកបណ្ឌិត **តាគ សុធា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិក |
| ១៤- | លោក **ថ្វាយ ម៉ុម** | ប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ | សមាជិក |
| ១៥- | លោក **យឹម ជុង** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច | សមាជិក |
| ១៦- | លោក **ម៉ៅ សារ៉ាយ** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ | សមាជិក |
| ១៧- | លោក **ពេជ្រ សេដ្ឋា** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៨- | លោក **លាត សំណាង** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ | សមាជិក |
| ១៩- | លោក **ឌី ដារាវុធ** | អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ | សមាជិក |
| ២០- | លោក **គង់ វ៉ាន់ដេត** | ប្រធានការិយាល័យសម្ភារៈ | សមាជិក |
| ២១- | គ្រប់នាយកគម្រោងសហប្រតិបត្តិការក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ | | សមាជិក |
| ២២- | គ្រប់ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត | | សមាជិក |

**ប្រការ ២ .–** គណៈកម្មការកណ្តាលធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងអភិវឌ្ឍន៍ជនបទ មានភារកិច្ចណែនាំ ត្រួតពិនិត្យការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតនៅក្រោមការគ្រប់គ្រង កាន់កាប់ និងប្រើប្រាស់របស់អង្គភាពថ្នាក់កណ្តាលនៃក្រសួងអភិវឌ្ឍន៍ជនបទ ឲ្យបានត្រឹមត្រូវតាមច្បាប់កំណត់ និងបូកសរុបលទ្ធផលដែលសម្រេចបាន ដើម្បីរាយការណ៍ជូនក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យបានទៀងទាត់ជារៀងរាល់ឆ្នាំ ។

**ប្រការ ៣ .–** គណៈកម្មការកណ្តាលធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងអភិវឌ្ឍន៍ជនបទ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

**ប្រការ ៤ .–** បង្កើតអនុគណៈកម្មការបច្ចេកទេសបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីធ្វើជាជំនួយការឲ្យគណៈកម្មការកណ្តាលធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សួស គង់** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **ហួត សារឹម** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-លោកបណ្ឌិត | **យ៉ាន់ ម៉ាន់ដឺលុច** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៤-លោក | **ឆាន សុម៉ារ៉ា** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ | សមាជិក |
| ៥-លោក | **ឌី ដារាវុធ** | អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក | **កិច្ច មានិត** | ប្រធានការិយាល័យកិច្ចការទូទៅ | សមាជិក |
| ៧-លោក | **គង់ ម៉ាន់ដេត** | ប្រធានការិយាល័យសម្ភារៈ | លេខាធិការ |

**ប្រការ ៥ .–** អនុគណៈកម្មការបច្ចេកទេសបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងអភិវឌ្ឍន៍ជនបទមានតួនាទីក្នុងការស្រង់ និងចងក្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងអភិវឌ្ឍន៍ជនបទជារៀងរាល់ឆ្នាំ តាមបណ្តាអង្គភាពថ្នាក់កណ្តាល និងថ្នាក់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ។

**ប្រការ ៦ .–** អនុគណៈកម្មការបច្ចេកទេសបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងអភិវឌ្ឍន៍ជនបទ មានភារកិច្ចដូចតទៅ÷

- ធ្វើជាសេនាធិការឲ្យគណៈកម្មការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌចាស់ និងស្រាវជ្រាវរាល់ទ្រព្យសម្បត្តិទាំងឡាយណា ដែលមានស្ថានភាពប្រែប្រួលក្នុងឆ្នាំ ដើម្បីកត់ត្រាឲ្យបានត្រឹមត្រូវច្បាស់លាស់ និងចងក្រងបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំបន្ទាប់ ឲ្យស្របតាមនីតិវិធីហិរញ្ញវត្ថុ

- ពិនិត្យវាយតម្លៃអំពីបរិមាណ និងគុណភាពទ្រព្យសម្បត្តិដែលកំពុងមានក្នុងឃ្លាំង ទ្រព្យសម្បត្តិកំពុងប្រើប្រាស់ទាំងអស់ ឲ្យបានត្រឹមត្រូវច្បាស់លាស់តាមស្ថានភាពនីមួយៗ
- វាយតម្លៃ និងស្នើសុំគណៈកម្មការកណ្ដាលធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីសុំជម្រះបញ្ជី ឬផ្ទេរឲ្យអង្គភាពប្រើប្រាស់ខាងក្រៅ តាមការចាំបាច់ជាក់ស្តែង
- រាយការណ៍ជាប្រចាំជូនគណៈកម្មការកណ្ដាលធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នូវរាល់សកម្មភាព និងលទ្ធផលការងារទាំងឡាយដែលបាន និងកំពុងអនុវត្ត ។

**ប្រការ ៧ .–** សេចក្ដីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨ .–** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន គ្រប់ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត គ្រប់អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ និង ៨ ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ជា សុផារ៉ា**

**កន្លែងទទួល**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*"ដើម្បីជូនជ្រាប"*

- ដូចប្រការ ១ ប្រការ ៤ និងប្រការ ៨

*"ដើម្បីអនុវត្ត"*